សុន្ទរកថារបស់ **ឯកឧត្តម ហ៊ីដេហ៊ីសា ហូរីណូអ៊ុជិ**
ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីសម្ពោធអគារសិក្សាថ្មីមួយខ្នងនៅអនុវិទ្យាល័យកែវពណ៌ ក្នុងស្រុកពួក ខេត្តសៀមរាប
**ថ្ងៃទី ០១ ខែធ្នូ ២០១៦**

- សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ
- សូមគោរព **ឯកឧត្តម សៀង ណាំ** តំណាងរាស្រ្តខេត្តសៀមរាប
- សូមគោរព **ឯកឧត្តម YANO Tetsuro** អតីតអនុរដ្ឋមន្រ្តីជាន់ខ្ពស់នៃក្រសួងការបរទេសជប៉ុន
- សូមគោរព **លោក TSUKADA Muneo** ព្រះចៅអធិការវត្តស៊ូហ្វូគុជិ ទីក្រុងអ៊ុស៊ូណុមីយ៉ា
- សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី!

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយ ដែលបានមកចូលរួមក្នុងពិធីសម្ពោធអគារសិក្សាមួយខ្នង នៅអនុវិទ្យាល័យកែវពណ៌ ជាមួយនឹងវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សៀង ណាំ** តំណាងរាស្រ្តខេត្តសៀមរាប **ឯកឧត្តម YANO Tetsuro** អតីតអនុរដ្ឋមន្រ្តីជាន់ខ្ពស់នៃក្រសួងការបរទេសជប៉ុន **លោក TSUKADA Muneo** ព្រះចៅអធិការវត្តស៊ូហ្វូគុជិ ទីក្រុងអ៊ុស៊ូណុមីយ៉ា និងភ្ញៀវកិត្តិយសទាំងអស់។ ជាបឋម ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប។

ដោយទទួលស្គាល់ពីសារៈសំខាន់នៃការអប់រំថា ជាគន្លឹះសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនោះ រដ្ឋាភិបាលជប៉ុន បាននឹងកំពុងបន្តគាំទ្រជំនួយឧបត្ថម្ភរបស់ខ្លួនដល់កម្ពុជាតាមរយៈគ្រោងការណ៍ជាច្រើនបែបដែលក្នុងនោះក៏មានគ្រោងការណ៍ជំនួយឧបត្ថម្ភឥតសំណងទ្រង់ទ្រាយតូច ហៅកាត់ថាគម្រោងគូសាណូណេ។ គម្រោងនេះ គឺជាគម្រោងលើកទី២ហើយ ដែលត្រូវបានផ្តល់ជូនដោយគម្រោងគូសាណូណេនៅក្នុងខេត្តសៀមរាបនេះ។

ខ្ញុំបានទទួលដំណឹងថា សិស្សានុសិស្សប្រមាណជា ២៣៣នាក់នៅអនុវិទ្យាល័យកែវពណ៌នេះ ត្រូវសិក្សានៅក្នុងបរិស្ថានសិក្សាដែលមិនមានស្ថេរភាព។ តែឥឡូវនេះ បានជំនួសមកវិញដោយអគារសិក្សាថ្មីមួយខ្នង មាន៥បន្ទប់ បំពាក់ទៅដោយបរិក្ខារសិក្សា ព្រមទាំងបង្គន់អនាម័យចំនួន២បន្ទប់ផងដែរ។

ខ្ញុំពិតជាមានសេចក្តីរីករាយក្រៃលែងដែលបានឃើញ សិស្សានុសិស្សនៃអនុវិទ្យាល័យកែវពណ៌នេះ អាចសិក្សានៅក្នុងអគារសិក្សាដែលប្រកបដោយសុវត្ថិភាព និងជាសុខភាព។ ខ្ញុំសង្ឃឹមថា អគារសិក្សាថ្មីនេះ នឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវល្អ ដើម្បីទុកជានិមិត្តរូបដ៏យូរអង្វែងមួយនៃទំនាក់ទំនងមិត្តភាព រវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជា។

ជាចុងក្រោយនេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរដោយស្មោះសរចំពោះលោក-អ្នកទាំងអស់ដែលបានរួមចំណែកធ្វើអោយគម្រោងនេះដំណើរការទៅដោយរលូន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កិច្ចសហប្រតិបត្តិការនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

**សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!**